ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង
ខេត្តបន្ទាយមានជ័យ

សំណុំរឿងព្រហ្មទណ្ឌលេខ : ១២០១
ចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០២០
ជំនុំជម្រះថ្ងៃទី : ១៧-កុម្ភៈ-២០២១
សាលក្រមលេខ : ១៣ "ឈ"/១២២
ចុះថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០២១

# សាលក្រមព្រហ្មទណ្ឌ
## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តបន្ទាយមានជ័យ

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តបន្ទាយមានជ័យ នាថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង ពីរ រសៀល។

បានប្រកាសសាលក្រមជាសាធារណៈ នាថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង បី រសៀល។

### សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ

- លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

- លោកស្រី [redacted] ជាព្រះរាជអាជ្ញារង

### ក្រឡាបញ្ជីសវនាការ

- កញ្ញា [redacted] ជាក្រឡាបញ្ជី

### មេធាវី

- លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted]ដារ៉ា ហៅ រក្សា
- កញ្ញា [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted]ដារ៉ា ហៅ រក្សា

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ១២០១ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលមានជនជាប់ចោទដូចខាងក្រោម ៖

១.ឈ្មោះ [redacted] ធារ៉ា ហៅ រតន្ត ភេទប្រុស កើតថ្ងៃ២០.០៩.១៩៩២ នីតិជន សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរជាងម៉ូតូ កម្រិតវប្បធម៌ថ្នាក់ទី៨ ទីកន្លែងកំណើតភូមិ [redacted] ណ ខេត្តបន្ទាយមានជ័យ អាសយដ្ឋានមុនពេលឃុំខ្លួនភូមិ [redacted] មានជ័យ ប្រពន្ធឈ្មោះ [redacted] កូន ០១នាក់ ឪពុកឈ្មោះ [redacted] ឡាំ (រស់) ម្តាយឈ្មោះ [redacted] ស្រីម៉ៅ (រស់) ទោសពីមុន **មាន (ធ្លាប់ជាប់ពន្ធនាគាររយៈពេល ០៣ឆ្នាំ០៦ខែ ករណីគ្រឿងញៀន)**។ (ក្នុងឃុំ)

(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ : ៦៦៨ ព្រ.ទ៣ "ប"/២០ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០)

ជាប់ចោទពីបទ **"ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន"** ប្រព្រឹត្តនៅសង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៥** និងមាត្រា **៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**២.ឈ្មោះ** [redacted] **ឡុង** ភេទប្រុស កើតឆ្នាំ១៩៨៥ នីតិជន សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ លក់ដូរម្ហូរ កម្រិតវប្បធម៌ថ្នាក់ទី៦ ទីកន្លែងកំណើត [redacted] ខេត្តបន្ទាយមានជ័យ ប្រពន្ធឈ្មោះ [redacted] **ចន្ទី** កូនចំនួន ០២នាក់ ឪពុកឈ្មោះ [redacted] **សំ** (រស់) ម្តាយឈ្មោះ [redacted] **សំ** (រស់) ទោសពីមុន **មាន (ធ្លាប់ជាប់ពន្ធនាគាររយៈពេល ០៣ ឆ្នាំ ករណីគ្រឿងញៀន)** ។ (ក្នុងឃុំ)

(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ : ៦៦៩ ព្រ.ទ៣ "ប"/២០ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០)

**៣.ឈ្មោះ** [redacted] **សំណាង** ភេទប្រុស កើតឆ្នាំ១៩៩៥ នីតិជន សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ តែងការ និងនេសាទ កម្រិតវប្បធម៌ថ្នាក់ទី៨ ទីកន្លែងកំណើតភូ [redacted] បន្ទាយមានជ័យ អាសយដ្ឋានមុនពេលឃុំខ្លួន [redacted] ខេត្តបន្ទាយមានជ័យ នៅលីវ ឪពុកឈ្មោះ [redacted] **យឿន** (ស្លាប់) ម្តាយឈ្មោះ [redacted] **សុខា** (រស់) ទោសពីមុន **គ្មាន**។ (ក្នុងឃុំ)

(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ : ៦៧០ ព្រ.ទ៣ "ប"/២០ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០)

ជាប់ចោទពីបទ **"ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន"** ប្រព្រឹត្តនៅសង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤** និងមាត្រា **៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៤.ឈ្មោះ [redacted] **ពីង ហៅ ពិញ** ភេទប្រុស កើតថ្ងៃទី១៧.១០.១៩៩១ នីតិជន សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកម្មករ កម្រិតវប្បធម៌ថ្នាក់ទី៣ ទីកន្លែងកំណើតភូមិ [redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋានមុនពេលឃុំខ្លួន [redacted] ខេត្តបន្ទាយមានជ័យ ប្រពន្ធឈ្មោះ [redacted] **សូនី** ឪពុកឈ្មោះ [redacted] **បាក់** (រស់) ម្តាយឈ្មោះ **វ៉ា** (រស់) ទោសពីមុន **ធ្លាប់ជាប់មណ្ឌលភ្នំបាក់ចំនួន ០៥ ខែ**។ (ក្នុងឃុំ)

(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ : ៦៧១ ព្រ.ទ៣ "ប"/២០ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០)

ជាប់ចោទពីបទ **"ចាត់ចែងឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន"** ប្រព្រឹត្តនៅសង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៤២ កថាខណ្ឌ១ និងកថាខណ្ឌ២** និងមាត្រា **៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**<u>អង្គហេតុកើតឡើងមានដូចតទៅ</u>** :

កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២០ កម្លាំងនគរបាលប្រឆាំងគ្រឿងញៀននៃអធិការដ្ឋាននគរបាលក្រុងសិរីសោភ័ណ បានចុះបង្ក្រាបករណីគ្រឿងញៀន នៅក្នុងមូលដ្ឋានសង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ



Scanned with CamScanner

[redacted] **ដាវីត** និងឈ្មោះ [redacted] **លីដា** ប្រាកដមែន។ ដូចនេះប្តឹងសុំឱ្យលោកចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនទាំងនេះទៅតាមច្បាប់ ជាការសន្និដ្ឋានគប្បីពិចារណា។

**៧**.លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីរបស់ខ្លួនឈ្មោះ [redacted] **ដាវីត** និងឈ្មោះ [redacted] **លីដា** បានសារភាពត្រង់ៗលើកនូវកំហុសរបស់ខ្លួន ខ្លួនសំណូមសុំឱ្យលោកប្រធានក្រុមប្រឹក្សាមេត្តាបន្ធូរបន្ថយទោសដល់កូនក្តីរបស់ខ្លួនផង គប្បីតុលាការនឹងលើកយកមកពិនិត្យ និងពិចារណាតាមផ្លូវច្បាប់ ។

៨.មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **ដាវីត** ភេទប្រុស កើតថ្ងៃទី០៨.០៩.២០០៣ និងឈ្មោះ [redacted] **លីដា** ភេទស្រី កើតឆ្នាំ២០០៤ ពីបទ **"ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន"** ប្រព្រឹត្តនៅភូមិភ្នំតូចត្បូង ឃុំភ្នំតូច ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៤០ កថាខណ្ឌ៤** និងមាត្រា **៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៩.ជនជាប់ចោទឈ្មោះ [redacted] **ដាវីត** និងឈ្មោះ [redacted] **លីដា** សុទ្ធតែជាអនីតិជន មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវលើអំពើប្រព្រឹត្តរបស់ខ្លួន ហើយអំពើនេះបានធ្វើអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម និងបំផ្លាញសតិអារម្មណ៍របស់ប្រជាពលរដ្ឋដែលប្រើប្រាស់ ដែលច្បាប់បញ្ញត្តិឱ្យទទួលខុសត្រូវព្រហ្មទណ្ឌជាធរមាន ។

**១០**.ទោះបីជាជនជាប់ចោទឈ្មោះ [redacted] **ដាវីត** និងឈ្មោះ [redacted] **លីដា** បានប្រព្រឹត្តកើតឡើងក៏ពិតប្រាកដមែន ដែលតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងក្រមព្រហ្មទណ្ឌ និងសន្ធិសញ្ញាស្តីពីការការពារកុមារ គឺបានផ្តល់ ផលប្រយោជន៍ទៅឱ្យអនីតិជន លើសពីនេះទៀតក៏បានផ្តល់នូវស្ថានសម្រាលទោស ដែលជាប្រយោជន៍ទៅឱ្យអនីតិជនដោយការកាត់បន្ថយនូវពាក់កណ្តាលនៃអតិបរមា និងត្រូវបន្ថយពាក់កណ្តាលនៃអប្បបរមាលើសពី១ថ្ងៃ តាមក្រមព្រហ្មទណ្ឌ។

**១១**.វត្ថុតាងដែលដកហូតមាន ទូរសព្ទចំនួន ០១គ្រឿង ម៉ាក VIVO ពណ៌សលាយផ្កាឈូក មានសភាពបែកអេក្រង់ដោយកន្លែង ម៉ាស៊ីនដំណើរការ(ចាស់) ដកហូតពីឈ្មោះ [redacted] **ដាវីត** រក្សាទុកនៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តបន្ទាយមានជ័យ **គប្បីរឹបអូស** តាមបញ្ញត្តិមាត្រា **៩៣** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## ហេតុដូចនេះសម្រេច

I. **ផ្តន្ទាទោសជនជាប់ចោទ ៖**

១.ឈ្មោះ [redacted] **ដាវីត** ភេទប្រុស កើតថ្ងៃទី០៨.០៩.២០០៣ សញ្ជាតិខ្មែរ អនីតិជន មុខរបរកម្មករ សាសនាគ្រិស្ត កម្រិតវប្បធម៌ថ្នាក់ទី១០ថ្មី ទីកន្លែងកំណើត [redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋានមុនពេលឃុំខ្លួ [redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] ភិន (រស់) ម្តាយឈ្មោះ [redacted] សាវរ៉េត (រស់) នៅលីវ ទោសពីមុន **ធ្លាប់ជាប់មណ្ឌលកែប្រែជីវិតថ្មីភ្នំបាក់ចំនួន ០៣ ខែ។** (ក្នុងឃុំ)

(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ : ៦២៧ ព្រ.ទ111-ឈ-/២០ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០)

**ដាក់ពន្ធនាគារកំណត់រយៈពេល ១៤ (ដប់បួន) ខែ** ពីបទ **"ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន"** ប្រព្រឹត្តនៅភូមិភ្នំតូចត្បូង ឃុំភ្នំតូច ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៤០ កថាខណ្ឌ៤** និងមាត្រា **៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ដោយឃាត់ខ្លួនបានជនសង្ស័យចំនួន ១៤ នាក់រួមមាន ១.ឈ្មោះ [redacted] ផារ៉ា ភេទប្រុស អាយុ ២៨ឆ្នាំ , ២.ឈ្មោះ [redacted] **សំណាង ហៅ ត្រឹម** ភេទប្រុស អាយុ ២៥ឆ្នាំ , ៣.ឈ្មោះ [redacted] **ឡុង** ភេទប្រុស អាយុ ២៥ឆ្នាំ ជាប់សង្ស័យជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន , ៤.ឈ្មោះ [redacted] **ពីង ហៅ ពិញ** ភេទប្រុស អាយុ ២២ឆ្នាំ ជាប់សង្ស័យចាត់ចែង និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន , ៥.ឈ្មោះ [redacted] **ហន** ភេទប្រុស អាយុ ២៣ឆ្នាំ , ៦.ឈ្មោះ [redacted] **កូស៊ី ហៅ ពៅ** ភេទប្រុស អាយុ ២០ឆ្នាំ , ៧.ឈ្មោះ [redacted] **សូនី** ភេទស្រី អាយុ ១៨ឆ្នាំ , ៨.ឈ្មោះ [redacted] **ឆៃលី** ភេទប្រុស អាយុ ២៩ឆ្នាំ , ៩.ឈ្មោះ [redacted] **បូរី** ភេទប្រុស អាយុ ២៩ឆ្នាំ , ១០.ឈ្មោះ [redacted] **សុជាតិ** ភេទប្រុស អាយុ ៤០ឆ្នាំ , ១១.ឈ្មោះ [redacted] **ស៊ីង ហៅ សាន់** ភេទប្រុស អាយុ ៣៥ឆ្នាំ , ១២.ឈ្មោះ [redacted] **កុសល់** ភេទប្រុស អាយុ ៣៨ឆ្នាំ , ១៣.ឈ្មោះ [redacted] **ស៊ីណុច** ភេទប្រុស អាយុ ២៦ឆ្នាំ និង១៤.ឈ្មោះ [redacted] **ជាលី** ភេទប្រុស ជាប់សង្ស័យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។ ឆ្លងកាត់ការសាកសួរនៅដំណាក់កាលសមត្ថកិច្ច ឈ្មោះ [redacted] **ពីង** បានឆ្លើយសារភាពថា ខ្លួនពិតជាធ្លាប់ទិញគ្រឿងញៀនពីឈ្មោះ ឡាំ ផារ៉ា និងឈ្មោះ ខាត់ សំណាង ប្រាកដមែន , ចំណែកឯឈ្មោះ យ៉ែម កុសល់ បានឆ្លើយសារភាពថា ខ្លួនពិតជាបានទិញគ្រឿងញៀនពីឈ្មោះ [redacted] **ឡុង** ប្រាកដមែន ហើយចំពោះឈ្មោះ [redacted] **សូនី** បានឆ្លើយសារភាពថា ខ្លួនពិតជាធ្លាប់បានទទួលគ្រឿងញៀនពីឈ្មោះ [redacted] **ពីង** យកមកប្រើប្រាស់ដោយមិនគិតថ្លៃប្រាកដមែន។ ក្រោយបញ្ចប់ការស៊ើបអង្កេត សមត្ថកិច្ចបានកសាងសំណុំរឿង បញ្ជូនមកកាន់អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យដើម្បីចាត់ការបន្តតាមនីតិវិធី។ នៅដំណាក់កាលអយ្យការអ្នកប្រើប្រាស់គ្រឿងញៀនចំនួន ០៩ នាក់រួមមាន ១.ឈ្មោះ [redacted] **ហន** ភេទប្រុស អាយុ ២៣ឆ្នាំ , ២. ឈ្មោះ [redacted] **កូស៊ី ហៅ ពៅ** ភេទប្រុស អាយុ ២០ឆ្នាំ , ៣.ឈ្មោះ [redacted] **សូនី** ភេទស្រី អាយុ ១៨ឆ្នាំ , ៤.ឈ្មោះ [redacted] **ឆៃលី** ភេទប្រុស អាយុ ២៩ឆ្នាំ , ៥.ឈ្មោះ [redacted] **បូរី** ភេទប្រុស អាយុ ២៩ឆ្នាំ , ៦.ឈ្មោះ [redacted] **សុជាតិ** ភេទប្រុស អាយុ ៤០ឆ្នាំ , ៧.ឈ្មោះ [redacted] **ស៊ីង ហៅ សាន់** ភេទប្រុស អាយុ ៣៥ឆ្នាំ , ៨.ឈ្មោះ [redacted] **កុសល់** ភេទប្រុស អាយុ ៣៨ឆ្នាំ និង៩.ឈ្មោះ [redacted] **ស៊ីណុច** ភេទប្រុស អាយុ ២៦ឆ្នាំ ត្រូវបានសម្រេចបញ្ជូនទៅបន្សាបសារធាតុញៀននៅមជ្ឈមណ្ឌលភ្នំបាក់ ហើយចំពោះឈ្មោះ [redacted] **ជាលី** ដែលមិនជាប់ពាក់ព័ន្ធ និងគ្មានសារធាតុញៀននៅក្នុងខ្លួននោះត្រូវបានព្រះរាជអាជ្ញាអនុញ្ញាតឱ្យវិលទៅលំនៅដ្ឋានវិញ តាំងពីដំណាក់កាលសមត្ថកិច្ច។

**បានឃើញ** : ដីកាសន្និដ្ឋានស្ថាពរលេខ : ១១៨៩ អ.យ. ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០។

**បានឃើញ** : ដីកាដំណោះស្រាយលេខ : ៤១ ពស.ព្រស(ញ)/២១ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១។

**បានឃើញ** : ដីកាចាត់តាំងក្រុមប្រឹក្សាចៅក្រមជំនុំជម្រះលេខ : ៥១ ពស.ព្រជ"ក"/២១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

**បានឃើញ** : ឯកសារនានាក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ : ១២០១ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ។

**បានឃើញ** : ការផ្តល់ និងការជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការ ដែលធ្វើឡើងអនុលោមតាមបញ្ញត្តិមាត្រា **២៩២** និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## <u>នាពេលសវនាការ</u> :

- ក្រោយពីបាន ស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ផារ៉ា ហៅ [illegible]**
- ក្រោយពីបាន ស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ឡុង**
- ក្រោយពីបាន ស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សំណាង**
- ក្រោយពីបាន ស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ពីង ហៅ ពិញ**



Scanned with CamScanner

- ក្រោយពីបាន ស្ដាប់អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] គុសល់
- ក្រោយពីបាន ស្ដាប់អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ស៊ីណុច
- ក្រោយពីបាន ស្ដាប់អំណានចម្លើយរបស់សាក្សីឈ្មោ [redacted] គុស៊ី
- ក្រោយពីបាន ស្ដាប់អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] សុនី
- ក្រោយពីបាន ពិនិត្យឯកសារ និង ភស្តុតាងនានាដែលពាក់ព័ន្ធនៅក្នុងសំណុំរឿងនេះ
- ក្រោយពីបាន ស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបាន ស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបាន ស្ដាប់សម្ដីចុងក្រោយរបស់ជនជាប់ចោទ
- ក្រោយពីបាន ពិនិត្យ ពិភាក្សា និងពិចារណា ត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្ត បន្ទាយមានជ័យ

## យល់ឃើញថា :

១.តាមរយៈដីកាដំណោះស្រាយ លេខ : ៤១ ពស.ព្រស(ញ)/២១ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ បានសម្រេចបញ្ជូនជនជាប់ចោទមកធ្វើការជំនុំជម្រះមានឈ្មោះដូចខាងក្រោម ៖

១.១.ឈ្មោះ [redacted] **ធារ៉ា ហៅ រតុា** ភេទប្រុស កើតថ្ងៃ២០.០៩.១៩៩២ ពីបទ "**ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**" ប្រព្រឹត្តនៅសង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤** និងមាត្រា **៤៥** នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

១.២.ឈ្មោះ [redacted] **ឡុង** ភេទប្រុស កើតឆ្នាំ១៩៨៥ និងឈ្មោះ [redacted] **សំណាង** ភេទប្រុស កើតឆ្នាំ១៩៩៥ ពីបទ "**ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**" ប្រព្រឹត្តនៅសង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤** និងមាត្រា **៤៥** នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

១.៣.ឈ្មោះ [redacted] **ពីន ហៅ ពិញ** ភេទប្រុស កើតថ្ងៃទី១៧.១០.១៩៩១ ពីបទ "**ចាត់ចែងឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**" ប្រព្រឹត្តនៅសង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៤២ កថាខណ្ឌ១ និងកថាខណ្ឌ២** និងមាត្រា **៤៥** នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

២.តាមចម្លើយបដិសេធរបស់ជនជាប់ចោទឈ្មោះ [redacted] **ធារ៉ា ហៅ រតុា** បានឆ្លើយនាពេលសវនាការថា : កាលពីថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ២០២០ ខ្លួនត្រូវបានសមត្ថកិច្ចចាប់ខ្លួន នៅផ្ទះរបស់ខ្លួន ពាក់ព័ន្ធករណីគ្រឿងញៀន ។ ក្រោយចេញពីពន្ធនាគារ ខ្លួននៅតែបន្តប្រើប្រាស់គ្រឿងញៀន ក៏ប៉ុន្តែខ្លួនមិនបានលក់គ្រឿងញៀនឱ្យអ្នកណានោះទេ ។ ខ្លួនពិតជាធ្លាប់ចូលលុយគ្នាជាមួយឈ្មោះ **ពីង** ដើម្បីទិញគ្រឿងញៀនយកមកប្រើប្រាស់ពិតប្រាកដមែន ដោយទិញម្ដងអស់ប្រាក់ចំនួន **៤០.០០០ (បួនម៉ឺន) រៀល** ហើយខ្លួនជាអ្នកទៅទិញដោយផ្ទាល់នៅរ៉ាវរថភ្លើងក្រុងសិរីសោភ័ណ ហើយយកមកប្រើប្រាស់នៅផ្ទះរបស់ខ្លួនចំនួន ២ ទៅ ៣ ដងហើយ។ ខ្លួនស្គាល់ឈ្មោះ [redacted] **ដាលី** (សង្សាររបស់ខ្លួន) និងឈ្មោះ [redacted] **ឡុង** (ជាអ្នកជិតខាង) ចំណែកឯឈ្មោះ [redacted] **គុស៊ី ហៅ ពៅ** ខ្លួនមិនស្គាល់នោះទេ ។ ពេលឃាត់ខ្លួនគឺសមត្ថកិច្ចមិនបានដកហូតគ្រឿងញៀនពីខ្លួននោះទេ ប៉ុន្តែ



Scanned with CamScanner

បានដកហូតកាំបិតពីខ្លួនចំនួន ០១ ដើម។ ចំពោះគ្រឿងញៀនចំនួន ០៩ កញ្ចប់ដែលសមត្ថកិច្ចដកហូតបាននោះ មិនមែនជារបស់ខ្លួនឡើយ។ ខ្លួនប្រើប្រាស់គ្រឿងញៀនចុងក្រោយកាលពីពាក់កណ្តាល **ខែតុលា ឆ្នាំ ២០២០** ដោយគ្រឿងញៀននេះ គឺខ្លួនចូលលុយជាមួយមិត្តភក្តិឈ្មោះ [redacted] **ពីង** ដោយខ្លួនជាអ្នកទិញគ្រឿងញៀន ហើយយកមកប្រើប្រាស់នៅផ្ទះរបស់ខ្លួន ។ តាមចម្លើយបដិសេធនេះពុំអាចធ្វើឱ្យតុលាការជឿជាក់បានឡើយ ព្រោះពុំមានភស្តុតាង ឬ សាក្សីណាមួយច្បាស់លាស់សម្រាប់ដោះបន្ទុកដើម្បីឱ្យខ្លួនរួចផុតពីការចោទប្រកាន់ឡើយ តែបើផ្អែកតាមរយៈចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ពីង ហៅ ពីង** បានឆ្លើយបញ្ជាក់ថា ខ្លួនពិតជាបានទិញថ្នាំញៀនពីឈ្មោះ [redacted] **ធារ៉ា** ចំនួន ០២ដង ដោយលើកទី០១ ទិញតម្លៃ **៤០.០០០(បួនម៉ឺន)រៀល** ហើយឈ្មោះ [redacted] **ធារ៉ា** បានឱ្យខ្លួនទៅយកនៅម្តុំដេប៉ូឈើជិតរង្វង់មូលស្រីគ្រប់ល័ក្ខ និងលើកទី០២ ទិញតម្លៃ ៥០.០០០(ប្រាំម៉ឺន)រៀល ដោយឈ្មោះ [redacted] **ធារ៉ា** ណាត់ឱ្យទៅយកនៅសាលារៀនខ្លាកូន នេះសរបញ្ជាក់ថាជនជាប់ចោទឈ្មោះ [redacted] **ធារ៉ា** ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន។

៣.តាមចម្លើយបដិសេធរបស់ជនជាប់ចោទឈ្មោះ [redacted] **ឡុង** បានឆ្លើយនាពេលសវនាការថា : ខ្លួនប្រើប្រាស់ថ្នាំញៀនប្រភេទម៉ាទឹកកករយៈពេលកន្លះខែមកហើយ។ កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ២០២០ សមត្ថកិច្ចឃាត់ខ្លួននៅផ្ទះរបស់ឈ្មោះ [redacted] **ធារ៉ា** ពាក់ព័ន្ធករណីគ្រឿងញៀន។ នៅថ្ងៃកើតហេតុនោះ បានជាខ្លួនមានវត្តមាននៅផ្ទះរបស់ឈ្មោះ [redacted] ធារ៉ា នោះ ដោយសារតែខ្លួនត្រូវយកលុយទៅសងឈ្មោះ [redacted] **ធារ៉ា** ចំនួន ២០០.០០០(ម្ភៃម៉ឺន)រៀល ដែលខ្លួនបានខ្ចីគាត់យកមកទិញម្ហូបលក់ដូរ។ ក្រោយពីចេញពីពន្ធនាគារ ខ្លួននៅតែបន្តប្រើប្រាស់គ្រឿងញៀន ក៏ប៉ុន្តែខ្លួនមិនបានលក់គ្រឿងញៀនឱ្យអ្នកណានោះទេ។ ខ្លួនពិតជាបានធ្លាប់ចូលលុយគ្នាជាមួយឈ្មោះ [redacted] កុសល់ ទិញគ្រឿងញៀនយកមកប្រើប្រាស់ប្រាកដមែន ដោយខ្លួនជាអ្នកទៅទិញគ្រឿងញៀន ទិញនៅម្តុំវ៉ារថភ្លើង ក្រុងសិរីសោភ័ណ។ ខ្លួនចូលលុយជក់គ្រឿងញៀនជាមួយឈ្មោះ [redacted] កុសល់ ម្តងៗចំនួន ២០.០០០(ពីរម៉ឺន)រៀល ហើយខ្លួនធ្លាប់ចូលលុយជក់គ្រឿងញៀនជាមួយឈ្មោះ [redacted] កុសល់ បានតែម្តងប៉ុណ្ណោះ។ តាមចម្លើយបដិសេធនេះពុំអាចធ្វើឱ្យតុលាការជឿជាក់បានឡើយ ព្រោះពុំមានភស្តុតាង ឬសាក្សីណាមួយច្បាស់លាស់សម្រាប់ដោះបន្ទុកដើម្បីឱ្យខ្លួនរួចផុតពីការចោទប្រកាន់ឡើយ តែបើផ្អែកតាមរយៈចម្លើយរបស់សាក្សីឈ្មោះ [redacted] **កុសល់** និងឈ្មោះ [redacted] **ស៊ីណុច** បានឆ្លើយប្រហាក់ប្រហែលគ្នាថា ពួកខ្លួនពិតជាបានទិញថ្នាំញៀនពីឈ្មោះ [redacted] **ឡុង** ប្រាកមែន នេះសរបញ្ជាក់ថាជនជាប់ចោទឈ្មោះ [redacted] **ឡុង** ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន។

៤.តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **សំណាង** បានឆ្លើយនាពេលសវនាការថា : ខ្លួនពិតជាប្រើប្រាស់ថ្នាំញៀនប្រាកដមែន។ នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ ខ្លួនបានទិញថ្នាំញៀនយកមកប្រើប្រាស់ ចំនួន ៤០.០០០(បួនម៉ឺន)រៀល ទៅ ៥០.០០០(ប្រាំម៉ឺន)រៀល ហើយក៏បានយកមករំលែកលក់ឱ្យទៅឈ្មោះ [redacted] **ពីង** បានចំនួន ១០.០០០(មួយម៉ឺន)រៀល។ នៅក្នុងរឿងនេះខ្លួនបានដឹងកំហុសហើយ ខ្លួនសំណូមពរសុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់រូបខ្លួនផង។

៥.តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **ពីខ ហៅ ពិញ** បានឆ្លើយនាពេលសវនាការថា : កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២០ សមត្ថកិច្ចបានឃាត់ខ្លួននៅលើភ្នំស្វាយ ពាក់ព័ន្ធ ករណីគ្រឿងញៀន។ ខ្លួនចេះប្រើប្រាស់គ្រឿងញៀនប្រភេទម៉ាទឹកកកអស់រយៈពេលយូរមកហើយ ដោយទិញពីឈ្មោះ [redacted] **ធារ៉ា** និងឈ្មោះ [redacted] **សំណាង** ក្នុងមួយលើកៗតម្លៃ ៤០.០០០(បួនម៉ឺន)រៀល ទៅ ៥០.០០០(ប្រាំម៉ឺន)រៀល ហើយទើបតែខានទិញពីពួកគាត់ជាងកន្លះខែនេះនោះទេ។ ចំពោះឈ្មោះ [redacted] **ឡុង** គឺខ្លួនមិនដែលទិញគ្រឿងញៀនពីគាត់នោះទេ។ ខ្លួនមិនដែលបានឱ្យគ្រឿងញៀនទៅឈ្មោះ [redacted] **សូនី** ប្រើប្រាស់នោះទេ។ លុយដែលខ្លួនទិញគ្រឿងញៀនកន្លងមកគឺ ខ្លួនចូលលុយគ្នាជាមួយឈ្មោះ [redacted] **ហន** និងឈ្មោះ [redacted] **កូស៊ី ហៅ ពៅ** ដោយពេលចូលលុយគ្នា

រួចមក គឺពួកខ្លួនទាំងបីនាក់ទៅទិញគ្រឿងញៀន ពីឈ្មោះ[redacted] ធារ៉ា ហើយឈ្មោះ[redacted] ធារ៉ា ពេលទទួលបានលុយពួកខ្លួនរួចហើយ ក៏យកលុយនេះទៅទិញគ្រឿងញៀនពីអ្នកលក់ផ្សេងបន្តទៀត។ ពេលឃាត់ខ្លួនរួច សមត្ថកិច្ចបានធ្វើតេស្តរកឃើញសារធាតុញៀននៅក្នុងខ្លួន។ នៅក្នុងរឿងនេះខ្លួនបានដឹងកំហុសហើយ ខ្លួនសំណូមពរសុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់រូបខ្លួនផង។

៦.តាមចម្លើយរបស់លោក [redacted] សៀន ជាអធិការរងទទួលផែនគ្រឿងញៀនបានឆ្លើយនាពេលសវនាការថា : ខ្លួនចុះទៅចាប់ឈ្មោះ[redacted] ធារ៉ា តាមចម្លើយរបស់ឈ្មោះ [redacted] ពីង ពេលចុះទៅដល់ខ្លួនក៏បានទំនាក់ទំនងជាមួយម្ចាស់បន្ទប់ រួចដើរទៅអើតតាមបន្ទប់ ស្រាប់តែឃើញឈ្មោះ[redacted] ធារ៉ា ដែលមានស្ពាយអាវខោប៊ូយពណ៌ខៀវ កម្លាំងខ្លួនក៏បានចូលទៅក៏មានការប្រតាយប្រតប់គ្នា ទើបឈ្មោះ [redacted] ធារ៉ា ក៏បានគ្រវែងអាវនោះចោល នៅក្នុងអាវនោះមានថ្នាំញៀនចំនួន ០៧កញ្ចប់ ដែលឈ្មោះ[redacted] ធារ៉ា បោះចោល និងចំនួន ០២កញ្ចប់ទៀតរកឃើញនៅក្រោមគ្រែមុខបន្ទប់របស់ឈ្មោះ ដាលី ដែលជាសង្សាររបស់ឈ្មោះ[redacted] ធារ៉ា។

៧.តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] កុសល់ និងឈ្មោះ [redacted] ស៊ីណុច បានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងនៅដំណាក់កាលអយ្យការប្រហាក់ប្រហែលគ្នាថា : ខ្លួនជាអ្នកប្រើប្រាស់គ្រឿងញៀន និងធ្លាប់ទិញគ្រឿងញៀនពីឈ្មោះ[redacted]ឡុង ប្រាកដមែន។

៨.តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] សុនី បានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងនៅដំណាក់កាលអយ្យការថា : ខ្លួនចេះប្រើប្រាស់គ្រឿងញៀនអស់រយៈពេល ០៣ខែមកហើយ ដោយគ្រឿងញៀនដែលខ្លួន ប្រើប្រាស់ គឺឈ្មោះ [redacted] ពីង ហៅ ពិញ ជាអ្នកទិញយកមកឱ្យខ្លួន នៅផ្ទះរបស់ឈ្មោះ [redacted] ពីង ដោយមិនគិតថ្លៃ។ ខ្លួនប្រើប្រាស់គ្រឿងញៀនចុងក្រោយកាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ២០២០ ដោយគ្រឿងញៀននេះ គឺឈ្មោះ [redacted] ពីង និងមិត្តភក្តិរបស់គាត់ចំនួន ០២នាក់ ជាអ្នកយកគ្រឿងញៀនមកឱ្យខ្លួនប្រើប្រាស់ ជាមួយគាត់នៅលើភ្នំស្វាយ ប្រាកដមែន។

៩.តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] កុស៊ី បានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងនៅដំណាក់កាលអយ្យការថា : ខ្លួនជាអ្នកប្រើប្រាស់គ្រឿងញៀន ដោយខ្លួនចូលលុយជាមួយឈ្មោះ [redacted] ហន និងឈ្មោះ [redacted] ពីង ហើយឈ្មោះ [redacted] ពីង ជាអ្នកទៅទិញផ្ទាល់ ប្រាកដមែន។

១០.តាមរយៈចម្លើយបដិសេធរបស់ជនជាប់ចោទឈ្មោះ [redacted] ធារ៉ា ហៅ អេក្រា និងឈ្មោះ [redacted] ឡុង ពុំមានភស្តុតាងណាមួយបញ្ជាក់ថាខ្លួនមិនបានលក់ដូរគ្រឿងញៀននោះទេ តែបើផ្អែកលើចម្លើយរបស់សាក្សី , របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងភស្តុតាងផ្សេងៗដែលមាននៅក្នុងសំណុំរឿង អាចធ្វើឱ្យតុលាការជឿជាក់បានថា ពិតជាមានករណីនៃអង្គហេតុ **"ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន"** ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ធារ៉ា ហៅ អេក្រា និងឈ្មោះ [redacted] ឡុង ប្រាកដមែន។

១១.តាមរយៈចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សំណាង មានលក្ខណៈច្បាស់លាស់ស៊ីសង្វាក់ទៅនឹងចម្លើយរបស់សាក្សី , របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងភស្តុតាងផ្សេងៗដែលមាននៅក្នុងសំណុំរឿង អាចធ្វើឱ្យតុលាការជឿជាក់បានថា ពិតជាមានករណីនៃអង្គហេតុ **"ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន"** ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] សំណាង ប្រាកដមែន។

១២.តាមរយៈចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ពីង ហៅ ពិញ មានលក្ខណៈច្បាស់លាស់ស៊ីសង្វាក់ទៅនឹងចម្លើយរបស់សាក្សី របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងភស្តុតាងផ្សេងៗដែលមាននៅក្នុងសំណុំរឿង អាចធ្វើឱ្យតុលាការជឿជាក់បានថា ពិតជាមានករណីនៃអង្គហេតុ **"ទាក់ទងឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន"** ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] សំណាង ប្រាកដមែន។

១៣.ផ្អែកតាមសកម្មភាព និងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ធារ៉ា ហៅ រក្សា** បានទិញគ្រឿងញៀនយកមកលក់បន្តដើម្បីបានប្រាក់ចំណេញ និងចំណេញបានថ្នាំញៀនប្រើប្រាស់ ដែលនេះជាអំពើ "**ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**" ដោយច្បាប់តម្រូវឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៥ និងមាត្រា ៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៤.ផ្អែកតាមសកម្មភាព និងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ឡុង** និងឈ្មោះ [redacted] **សំណាង** បានទិញគ្រឿងញៀនយកមកលក់បន្តដើម្បីបានប្រាក់ចំណេញ និងចំណេញបានថ្នាំញៀនប្រើប្រាស់ ដែលនេះជាអំពើ "**ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**" ដោយច្បាប់តម្រូវឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤ និងមាត្រា ៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៥.ផ្អែកតាមសកម្មភាព និងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ពីង ហៅ ពិញ** បានទិញគ្រឿងញៀនយកមកប្រើប្រាស់ ព្រមទាំងបានចាត់ចែងឱ្យអ្នកដទៃប្រើប្រាស់ជាមួយខ្លួនដែរ ដែលនេះជាអំពើ "**ចាត់ចែងឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**" ដោយច្បាប់តម្រូវឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៤២ កថាខណ្ឌ១ និងកថាខណ្ឌ២ និងមាត្រា ៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៦.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ៖ ក្រោយពីបានបញ្ចប់ការសួរដេញដោលនាពេលសវនាការ តំណាងអយ្យការស្នើសុំរក្សាបទចោទប្រកាន់នៅដដែល និងស្នើសុំឱ្យផ្តន្ទាទោសជនទាំងនេះ ទៅតាមច្បាប់ ជាការសន្និដ្ឋានគប្បីពិចារណា។

១៧.លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីរបស់ខ្លួនឈ្មោះ [redacted] **ធារ៉ា ហៅ រក្សា** មិនបានប្រព្រឹត្តអំពើ "**ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន**" ឡើយ គឺកូនក្តីរបស់ខ្លួនគ្រាន់តែ "**ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**" ប៉ុណ្ណោះ ខ្លួនសំណូមសុំឱ្យលោកប្រធានក្រុមប្រឹក្សាមេត្តាបន្ធូរបន្ថយទោសដល់កូនក្តីរបស់ខ្លួនផង គប្បីតុលាការនឹងលើកយកមកពិនិត្យ និងពិចារណាតាមផ្លូវច្បាប់ ។

១៨.តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ **២៩៩៩០/២១ ម.ព.អ.ជ.ប.គ.ញ** ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឃើញថាថ្នាំញៀនដែលដកហូតបានពីជនត្រូវចោទឈ្មោះ [redacted] **ធារ៉ា ហៅ រក្សា** បង្ហាញថាមានវត្តមានសារធាតុញៀន ជាប្រភេទក្រាមម្សៅថ្លា ពណ៌ស ឈ្មោះមេតំហ្វេតាមីន ដែលស្ថិតនៅក្នុងតារាងទី២ មាត្រា៥ នៃចំណាត់ថ្នាក់គ្រឿងញៀន ដែលមានទម្ងន់សរុបចំនួន **៤១.៧១ក្រាម(សាច់ថ្នាំសុទ្ធ)** និងមានកម្រិតភាពសុទ្ធចំនួន **៧៩.២៣%** ដូច្នេះការគណនារកកម្រិតជាតុសុទ្ធសរុបគឺ **(៤១.៧១ក្រាម × ៧៩.២៣%) ÷ ១០០ = ៣៣.០៤៦៨ក្រាម (ឃើញថាលើ ១៥ ក្រាម)** ។

១៩.មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **ធារ៉ា ហៅ រក្សា** ភេទប្រុស កើតថ្ងៃ២០.០៩.១៩៩២ ពីបទ "**ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**" ប្រព្រឹត្តនៅសង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៥** និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២០.មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **ឡុង** ភេទប្រុស កើតឆ្នាំ១៩៨៥ និងឈ្មោះ [redacted] **សំណាង** ភេទប្រុស កើតឆ្នាំ១៩៩៥ ពីបទ "**ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**" ប្រព្រឹត្តនៅសង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤** និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២១.មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **ពីង ហៅ ពិញ** ភេទប្រុស កើតថ្ងៃទី១៧.១០.១៩៩១ ពីបទ "**ចាត់ចែងឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**" ប្រព្រឹត្តនៅ

សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិ មាត្រា **៤២ កថាខណ្ឌ១ និងកថាខណ្ឌ២** និងមាត្រា **៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**២២.**ជនជាប់ចោទឈ្មោះ [redacted] **ឆារ៉ា ហៅ រក្សា** , ឈ្មោះ [redacted] **ឡុខ** , ឈ្មោះ [redacted] **សំណាង** និង ឈ្មោះ [redacted] **ពីង ហៅ ពិញ** សុទ្ធតែជានីតិជន មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវលើអំពើ ប្រព្រឹត្តរបស់ខ្លួន ហើយអំពើនេះបានធ្វើអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម និងបំផ្លាញ សតិអារម្មណ៍របស់ប្រជាពលរដ្ឋដែលប្រើប្រាស់ ដែលច្បាប់បញ្ញត្តិឱ្យទទួលខុសត្រូវព្រហ្មទណ្ឌជាធរមាន ។

**២៣.**វត្ថុតាងដែលដកហូតមាន ៖

.ថ្នាំញៀនប្រភេទក្រាមម្សៅថ្លា ពណ៌ស ចំនួន ០១កូនថង់ មានទម្ងន់សរុបស្មើនឹង ៣៤.៧០ (សាមសិបបួនកណ្តក់សញ្ញាចិតសិប)ក្រាម ថ្លឹងសាច់ថ្នាំសុទ្ធ ច្រកចូលទៅក្នុងស្រោមសំបុត្រពណ៌ស ចំនួន ០១ ដែលដកហូតពីឈ្មោះ [redacted] **ឆារ៉ា ហៅ រក្សា** ។

.ម៉ូតូ ០១គ្រឿង ម៉ាក Smash V ពណ៌ខ្មៅ សភាពចាស់ គ្មានអាវ គ្មានគំរប (មានតែគ្រោង) លេខតួរលុប ដែលដកហូតពីឈ្មោះ [redacted] **ឆារ៉ា ហៅ រក្សា** ។

.ទូរសព្ទចំនួន ០៤គ្រឿង ម៉ាក OPPO ពណ៌ខ្មៅ បែកអេក្រង់មុខ(ជាប់លេខសម្ងាត់) និង ស្រោមពណ៌ប្រផេះ , ម៉ាក honor ពណ៌ខ្មៅ បែកអេក្រង់មុខ សភាពចាស់ , ម៉ាក ណូគា អ៊ិនចុចពិល ពណ៌ខ្មៅ សភាពចាស់ចំនួន ០២គ្រឿង ដែលដកហូតពីឈ្មោះ [redacted] **ឆារ៉ា ហៅ រក្សា** ។

.ជញ្ជីងចំនួន ០១ , ដាវសាំម៉ូរ៉ៃ ចំនួន ០១ដើម ប្រវែង ៥៣សង់ទីម៉ែត្រ ដែលដកហូតពីឈ្មោះ [redacted] **ឆារ៉ា ហៅ រក្សា** ។

.ទូរសព្ទចំនួន ០១គ្រឿង ម៉ាក Samsung ពណ៌ស សភាពចាស់ និងស្រោមពណ៌ខ្មៅចំនួន ០១ ដែលដកហូតពីឈ្មោះ [redacted] **សំណាង** ។

.កូនកាបូបចំនួន ០១គ្រឿង ពណ៌ខ្មៅ និងឧបករណ៍សម្រាប់ជក់គ្រឿងញៀនមួយចំនួន ដែល ដកហូតពី **អញ្ញត្តជន** ។

រក្សាទុកនៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តបន្ទាយមានជ័យ **គប្បីរឹបអូស** តាមបញ្ញត្តិមាត្រា **៩៣** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## <u>ហេតុដូចនេះសម្រេច</u>

I. **ផ្តន្ទាទោសជនជាប់ចោទ ៖**

**១.**ឈ្មោះ [redacted] **ឆារ៉ា ហៅ រក្សា** ភេទប្រុស កើតថ្ងៃ២០.០៩.១៩៩២ នីតិជន សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរជាងម៉ូតូ កម្រិតវប្បធម៌ថ្នាក់ទី៨ ទីកន្លែងកំណើតភូមិ [redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋានមុនពេលឃុំខ្លួន [redacted] ខេត្ត បន្ទាយមានជ័យ ប្រពន្ធឈ្មោះ [redacted] កូន ០១នាក់ ឪពុកឈ្មោះ [redacted] **ឡាំ** (រស់) ម្តាយឈ្មោះ [redacted] **ស្រីម៉ៅ** (រស់) ទោសពីមុន **មាន (ធ្លាប់ជាប់ពន្ធនាគាររយៈពេល ០៣ឆ្នាំ០៦ខែ ករណីគ្រឿងញៀន)**។ (ក្នុងឃុំ)

(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ : ៦៦៨ ព្រ.ទ|||"ថ"/២០ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០)

**ដាក់ពន្ធនាគារកំណត់រយៈពេល ០៦ (ប្រាំមួយ) ឆ្នាំ** ពីបទ **"ជួញដូរ និងប្រើប្រាស់ ដោយខុសច្បាប់នូវសារធាតុញៀន"** ប្រព្រឹត្តនៅសង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៥** និងមាត្រា **៤៥** នៃ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned with CamScanner

២.ឈ្មោះ [redacted] ឡុង ភេទប្រុស កើតឆ្នាំ១៩៨៥ នីតិជន សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរលក់ដូរម្ហូរ កម្រិតវប្បធម៌ថ្នាក់ទី៦ ទីកន្លែងកំណើតជាំ [redacted] ខេត្តបន្ទាយមានជ័យ ប្រពន្ធឈ្មោះ [redacted] ធន្នី កូនចំនួន ០២នាក់ ឪពុកឈ្មោះ [redacted] សំ (រស់) ម្ដាយឈ្មោះ [redacted] សំ (រស់) ទោសពីមុន **មាន (ធ្លាប់ជាប់ពន្ធនាគាររយៈពេល ០៣ឆ្នាំ ករណីគ្រឿងញៀន)**។ (ក្នុងឃុំ)

(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ : ៦៦៩ ព្រ.ទ៣/ប៉/២០ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០)

**ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ (បី) ឆ្នាំ** ពីបទ **"ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន"** ប្រព្រឹត្តនៅសង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤** និងមាត្រា **៤៥** នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

៣.ឈ្មោះ [redacted] **សំណាង ហៅ ត្រឹម** ភេទប្រុស កើតឆ្នាំ១៩៩៥ សញ្ជាតិខ្មែរ មុខរបរតែងការ ទីកន្លែងកំណើតនៅ [redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋានមុនពេលឃុំខ្លួនបណ្ដោះអាសន្ន [redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] **យឿម "ស្លាប់"** ម្ដាយឈ្មោះ [redacted] **សុខា "រស់"** ជានីតិជន ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការពីមុន **គ្មាន** ។ **(ក្នុងឃុំ)**

(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ : ៦៧០ ព្រ.ទ៣/ប៉/២០ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០)

**ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ) ឆ្នាំ ០៦ (ប្រាំមួយ) ខែ** ពីបទ **"ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន"** ប្រព្រឹត្តនៅសង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤** និងមាត្រា **៤៥** នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

៤.ឈ្មោះ [redacted] **ពីង ហៅ ពិញ** ភេទប្រុស កើតថ្ងៃទី១៧.១០.១៩៩១ នីតិជន សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកម្មករ កម្រិតវប្បធម៌ថ្នាក់ទី៣ ទីកន្លែងកំណើតភូមិ [redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋានមុនពេលឃុំខ្លួនភូមិ [redacted] ខេត្តបន្ទាយមានជ័យ ប្រពន្ធឈ្មោះ [redacted] សូនី ឪពុកឈ្មោះ [redacted] **បាក់** (រស់) ម្ដាយឈ្មោះ **វ៉ា** (រស់) ទោសពីមុន **ធ្លាប់ជាប់មណ្ឌលភ្នំបាក់ចំនួន ០៥ ខែ**។ (ក្នុងឃុំ)

(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ : ៦៧១ ព្រ.ទ៣/ប៉/២០ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០)

**ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ) ឆ្នាំ** ពីបទ **"ទាត់ទែងឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន"** ប្រព្រឹត្តនៅសង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៤២ កថាខណ្ឌ១ និងកថាខណ្ឌ២** និងមាត្រា **៤៥** នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

II. **វត្ថុតាងដែលដកហូតមាន៖**

**១.**ថ្នាំញៀនប្រភេទក្រាមម្សៅថ្លា ពណ៌ស ចំនួន ០១កញ្ចប់ មានទម្ងន់សរុបស្មើនឹង ៣៤.៧០ (សាមសិបបួនកណ្ដក់សញ្ញាចិតសិប)ក្រាម ថ្លឹងសាច់ថ្នាំសុទ្ធ ច្រកចូលទៅក្នុងស្រោមសំបុត្រពណ៌ស ចំនួន ០១ ដែលសល់ពីការដេកសំណាក ដកហូតពីឈ្មោះ [redacted] **ធារ៉ា ហៅ អេក្រា** ។

**២.**ម៉ូតូ ០១គ្រឿង ម៉ាក Smash V ពណ៌ខ្មៅ សភាពចាស់ គ្មានអាវ គ្មានគំរប (មានតែគ្រោង) លេខតួរលុប ដែលដកហូតពីឈ្មោះ [redacted] **ធារ៉ា ហៅ អេក្រា** ។



Scanned with CamScanner

៣.ទូរសព្ទចំនួន ០៤គ្រឿង ម៉ាក OPPO ពណ៌ខ្មៅ បែកអេក្រង់មុខ(ជាប់លេខសម្ងាត់) និងស្រោមពណ៌ប្រផេះ , ម៉ាក honor ពណ៌ខ្មៅ បែកអេក្រង់មុខ សភាពចាស់ , ម៉ាក ណូគា អ៊ិនចុចពិល ពណ៌ខ្មៅ សភាពចាស់ចំនួន ០២គ្រឿង ដែលដកហូតពីឈ្មោះ [redacted]**ធារ៉ា ហៅ រក្សា** ។

៤.ជញ្ជីងចំនួន ០១ , ដាវសាំម៉ូរ៉ៃ ចំនួន ០១ដើម ប្រវែង ៥៣សង់ទីម៉ែត្រ ដែលដកហូតពីឈ្មោះ [redacted]**ធារ៉ា ហៅ រក្សា** ។

៥.ទូរសព្ទចំនួន ០១គ្រឿង ម៉ាក Samsung ពណ៌ស សភាពចាស់ និងស្រោមពណ៌ខ្មៅចំនួន ០១ ដែលដកហូតពីឈ្មោះ [redacted]**សំណាង** ។

៦.កូនកាបូបចំនួន ០១គ្រឿង ពណ៌ខ្មៅ និងឧបករណ៍សម្រាប់ជក់គ្រឿងញៀនមួយចំនួន ដែលដកហូតពី **អញ្ញត្តជន**។

រក្សាទុកនៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តបន្ទាយមានជ័យ **ត្រូវរឹបអូស** តាមបញ្ញត្តិមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

III. សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ធារ៉ា ហៅ រក្សា** , ឈ្មោះ [redacted]**ឡុង** , ឈ្មោះ [redacted]**សំណាង** និងឈ្មោះ [redacted]**ពីង ហៅ ពិញ** ។

បើកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់របស់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃព្រហស្បតិ៍ ៥កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១

**ក្រឡាបញ្ជីសវនាការ**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner